

# វិធានការ សម្លុត

ការបញ្ជូន សមាជិក គណបក្សសង្គ្រោះជាតិ ១១ នាក់ ទៅដាក់គុកព្រៃសវិញ ជាវិធានការ សម្លុត របស់ ហ៊ុន-សែន ដល់ តំណាង គណបក្សសង្គ្រោះជាតិ នៅក្នុងរដ្ឋសភា ឬ ផ្ទះ ឈាង-វុន ដែលមានជាប់នូវការចោទជាទោស ពីតុលាការ ហ៊ុន-សែន ជាពិសេស លោក គីម-សុខា, អ៊ុំ-សំអាត និង សកម្មជន ដែល កំពុង ខ្វល់ខ្វាយជាសកម្ម អំពី បញ្ហា ព្រំដែន ខ្មែរ-យៀកណាម។

វិធានការ ហ្នឹះ ក៏បង្ហាញកាត់តែច្បាស់ អោយឃើញដែរថា តួនាទី លោក សម -រង្សី ជា អ្នកសន្ទនានយោបាយ ជាផ្លូវការ ជាមួយ ហ៊ុន-សែន វាមានតម្លៃ ត្រឹមតែ ស៊ីផឹក បាយ ទឹក នៅក្នុងភាជនីយដ្ឋានតែប៉ុណ្ណោះ។

ហ៊ុន-សែន ជ្រើសរើស ថ្ងៃខួបឆ្នាំ កិច្ចព្រមព្រៀង នយោបាយ ២២ កក្កដា ឆ្នាំ ២០១៤រវាង គណបក្សសង្គ្រោះជាតិ ជាមួយនឹង ប្រជាជន នេះ គឺជាការ «អោយក្ត» ដល់ សម-រង្សី តែម្តងព្រោះសម-រង្សី តែងតែនិយាយប្រាប់ ហ៊ុន-សែន ថាខ្លួនជា បាមោក្ខ (meneur ou chef) មានឥទ្ធិពលណាស់លើ គណបក្សខ្លួន អាចនឹងបង្ក្រាបបានដល់សមាជិកណាដែលដើរខុសចង្វាក់គំនិតនយោបាយខ្លួន។ ការប្រមាថ របស់ ហ៊ុន-សែន នេះ ក៏ផ្ញើទៅគណបក្សសង្គ្រោះជាតិដែរ ក្នុងនោះ មានអ្នកដឹកនាំមួយចំនួន សម្ញុំ ស៊ីបុណ្យស័ក្ត ដែល ហ៊ុន-សែន ចែកចាយឲ្យ ដូចជា អនុប្រធានរដ្ឋសភា ប្រធាន គណកម្មាធិការ នានា ក្នុងរដ្ឋសភា ឈាង-វុន។ សូមបើរង់ក្រចក៖ អស់លោកទាំងនោះ មានដែរសួរសំនួរ ឯកឯងថា មាន រដ្ឋសភា ណាមួយ ក្នុងនោះមានពហុបក្ស ដែលគណបក្សនិមួយៗ គេមានអ្នកនាំពាក្យ របស់គេ តែបែរ ជាមានបន្ថែម អ្នកនាំពាក្យ រដ្ឋសភា មួយទៀត ហើយអ្នកនាំពាក្យនេះ ដើរតួខ្លួន ជានាយប៉ូលីស ឬ ម្ចាស់ផ្ទះ តែម្តង។ ពួកអស់លោក បិទមាត់ ចំពោះករណីនេះ ព្រោះ ពួកអស់លោក ខ្លាច ឈាង-វុន។ សេចក្តីខ្លាចនេះគឺដូចហ្វូងក្របីព្រៃរាប់រយ (៥៥នាក់) នាំគ្នាឈរមើល តោមួយក្បាល (ឈាង-វុន) ចាប់ស៊ី ក្របីមួយក្បាល (អ៊ុំ-សំអាត) នោះឯង។ បើពួកអស់លោក គ្មានហ៊ានមាន ប្រតិកម្ម នឹងអំពើខុសច្បាប់នេះទេ តើតួនាទីរបស់អស់លោក នៅក្នុង រដ្ឋសភា វាមានប្រយោជន៍ អ្វីទៅ ? ដូច្នេះ រដ្ឋសភានេះ គឺពិតជារដ្ឋសភា ឈាង-វុន នោះហើយ។

ក្នុង ករណី បញ្ជូន សមាជិក គណបក្សសង្គ្រោះជាតិ ទៅគុកព្រៃស វិញ នេះ យើងមាន ជំនឿថា, ហើយសូមឲជំនឿយើង វាខុសទៅចុះ, លោកសម-រង្សី គាត់ មិនហ៊ានមាន ប្រតិកម្មអ្វីនោះឡើយ ព្រោះគាត់បានក្លាយទៅជា ខ្ញុំបំរើ របស់ លោក ហ៊ុន-សែន រួចទៅហើយ បើ ចៅហ្វាយ ក្រោធខឹង នឹងគាត់ ហើយ អោយក្ត ដល់គាត់ គឺគាត់ ច្បាស់ជា

ដោយ ឧប សៅ សង្ហា
២២ កក្កដា ២០១៥

ទទួលយក រត់ទៅប្តូននៅបរទេស សម្ងំថីន ចាំ លោក ធំ ឲគាត់បាត់ខឹងសិន រួច សុំ ទៅសូមទោស សូមរក្សាវប្បធម៌សន្ទនា របស់គាត់ ដែល វាក្លាយទៅជា ល្បែង លេងសើច របស់ហ៊ុន-សែន ទៅហើយ។ បើ វប្បធម៌សន្ទនា របស់ លោក សម-រង្ស៊ី វាលែងបំរើបុព្វហេតុប្រយោជន៍ជាតិ ទៅហើយ តើ ហេតុអ្វី ក៏ លោក សម-រង្ស៊ី ខំរក្សាទុកវា ? យើងមិនបាច់ឆ្លើយនឹង សំនួរនេះទេ ព្រោះអំពើរបស់ លោក សម-រង្ស៊ី ដែលគាត់កំពុងធ្វើសព្វថ្ងៃនេះ វាជាចម្លើយ រួចទៅហើយ។ឧទាហរណ៍ វិធានការ សម្លុត របស់ លោក ហ៊ុន-សែន ក៏ជាចម្លើយមួយដែរ ព្រោះហ៊ុន-សែន ដឹកច្បាស់ណាស់ ថា សម-រង្ស៊ី ជាមនុស្ស កំសាកបំផុត ដែលគាត់អាចទុកបន្តឲដើរតួជា បាវបំរើ ប្រយោជន៍ គាត់បាន។ តែប្រយោជន៍ ហ៊ុន-សែន វាអាចមានបាន លុះត្រាតែ ហ៊ុន-សែន សម្លុត ខ្មែរគ្នាឯង ដើម្បី បង្ហាញ សេវគតិភាព ចំពោះយៀកណាមដែលខ្លួនជាអាយ៉ងដាច់ថ្លៃ។ រឿងព្រំដែន ដែល ហ៊ុន-សែន កំពុង ដោះស្រាយ វាគ្រាន់តែជា ការភូតភរ ទុកឲយួន មានពេលជាន់ករខ្មែរបន្ថែមទៀត។ វាមិនដែលមាន អ្នកដឹកនាំណា ចង់ប្រឈរមុខទល់នឹងការឈ្លានពានយៀកណាមបែរជាចាប់ខ្មែរគ្នាឯងដាក់គុក។ នេះហើយ ការពិត របស់ សមមិត្ត ហ៊ុន-សែន តើវាខុសអ្វីនឹង ប៉ុល-ពត ? វាចង់ច្បាំងនឹងយួន តែបែរជាសម្លាប់ខ្មែរគ្នាឯង។ ហ៊ុន-សែន មិនអាចលាក់ពុតបាននោះឡើយ ដូចពាក្យចាស់ ពោលថា «ឆ្កែកន្ទុយខ្វៀន វានៅតែខ្វៀនជានិច្ច»។

លោក គីម-សុខា និយាយត្រូវ ថា លោក ហ៊ុន-សែន និង សម- រង្ស៊ី ជាអ្នកទទួលខុសត្រូវចំពោះ ការបញ្ជូន សមាជិក សង្គ្រោះជាតិ ១១ នាក់ ទៅដាក់គុក ព្រៃស វិញ ព្រោះលោកទាំងពីរ ជា ដៃគូ នៃកិច្ចព្រមព្រៀង នយោបាយ ថ្ងៃទី ២២ កក្កដា ២០១៤ តែ លោកភ្លេចគិតថា បុណ្យស័ក្ក របស់លោក ជា អនុប្រធានរដ្ឋសភា ឈាង-វុន ក៏បានមកពីកិច្ចព្រមព្រៀងនេះដែរ ដូច្នេះ បើ លោក មាន សេចក្តីក្លាហ៊ាន ជាអ្នកដឹកនាំ លោក ត្រូវដាក់ពាក្យលាលែងពីដំណែងនេះ តែបើ លោក មិនធ្វើ គឺ លោក ច្បាស់ជា អ្នកទទួលខុសត្រូវពេញមុខ ដូច សម-រង្ស៊ី និង ហ៊ុន-សែន ដែរ។ លោក គីម-សុខា គួរដឹងដែរថា បើរស់នៅក្នុង អាង លាមក ជាមួយ គេឯងហើយ គឺច្បាស់ ជា ជាប់ ក្លិនស្អុយ ដូចគេឯង ទោះបីលោកតាំងខ្លួនលោក ជា មាស់ ទឹកដប់ក៏ដោយ។ តែពួកអ្នកដឹងនាំ គណបក្សសង្គ្រោះជាតិ គាត់ដូចជា ហ្វូងក្របីព្រៃ នោះឯង គឺនាំគ្នាឈរមើល តោបីបួនក្បាល ខាំស៊ីគ្នាគាត់ តែ ពួកគាត់ នៅតែ រក្សាទុក វប្បធម៌សន្ទនា ខ្សឹបៗ នៅក្នុងភោជនីយដ្ឋានដដែល ដើម្បី រក្សា តំណែង របស់ពួកគាត់ នៅក្នុងរដ្ឋសភា តែប៉ុណ្ណោះ។ រឿងនេះ វាមិនដូច អ្នកវិភាគនយោបាយ រស់ នៅក្នុងទ្រុង យៀកណាម ថាវានាំឲ សន្ទាភាពនយោបាយមាន កម្តៅ ឡើងវិញ។ តាមពិត វាគ្មានអ្វីដូរ នោះទេ ព្រោះរឿងនយោបាយ នៅស្រុក

ដោយ ឧប សៅ សង្ខា
២២ កក្កដា ២០១៥

ខ្មែរ វាជា រឿង កំប្លែង លេងសើច តែប៉ុណ្ណោះ រហូត ដល់ពេលស្រុកខ្មែរ ក្លាយជាខេត្តយួន ទើបនាំគ្នា ឈប់សើច ហើយ អង្គុយយំ តែវាហួសពេលវេលាទៅហើយ។

ដោយ ឧប សៅ សង្ហា
២២ កក្កដា ២០១៥